**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសព័ត៌មានស្តីពី
# បេសកកម្មចូលរួមពិនិត្យបទឈប់បាញ់នៅតំបន់ព្រំដែន និងជម្រកបណ្តោះអាសន្នជនភៀសសឹក

* * * * * * * * * * *

ចាប់ពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៥ វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បានចូលរួមក្នុងបេសកកម្មដើម្បីពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងបទឈប់បាញ់ដែលបានចូលជាធរមាននៅពាក់កណ្តាលអាធ្រាត្រថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងវាយតម្លៃស្ថានភាពព្រំដែនកម្ពុជា-ថៃ និងការខូចខាតពីសារការបំផ្លិចបំផ្លាញដោយកងទ័ពថៃពីការបាញ់ផ្លោងពីកាំភ្លើងធំនិងរ៉ុកកែត ការវាយប្រហារដោយប្រើយន្តហោះចំបាំង F-16 គ្រាប់បែកចង្កោម និងសំណល់នៃគ្រាប់មិនទាន់ផ្ទុះ (UXO)។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ យើងខ្ញុំបានចូលរួមដំណើរទស្សនៈកិច្ចនៅតំបន់អានសេះ ដោយមានការចូលរួមពីអនុព័ន្ធយោធាមកពី ១៣ ប្រទេស មន្ត្រីក្រសួងការពារជាតិ និងអង្គការសង្គមស៊ីវិល រួមទាំងតំណាងអ្នកសារព័ត៌មាន និងបំពេញបេសសកម្មនៅខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ចាប់ពីថ្ងៃទី ០១-០២ ខែសីហា ឆ្នាំ២០២៥ ដោយមានការចូលរួមពីប្រមុខការទូតនៃព្រះរាជាណាចក្រកម្ពុជាចំនួន ២២ រូប តំណាងស្ថានបេសកកម្មអង្គការសហប្រជាជាតិ តំណាងជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធ។ បេសកកម្មនេះមានគោលបំណងវាយតម្លៃស្ថានភាពក្រោយជម្លោះ និងមជ្ឈមណ្ឌលជនភៀសខ្លួនស៊ីវិលដែលបានផ្លាស់ទីលំនៅបន្ទាប់ពីការប៉ះទង្គិចគ្នាដោយប្រដាប់អាវុធនាពេលថ្មីៗនេះរវាងកម្ពុជា និងថៃ។

នៅថ្ងៃទី៣០ ខែកក្កដា វិទ្យាស្ថាន AVI បានចូលរួមក្នុងបេសកកម្មនេះជាមួយអនុព័ន្ធយោធាតំណាងឱ្យមហាអំណាចអន្តរជាតិ និងរដ្ឋសមាជិកអាស៊ានសរុបមកពី ១៣ ប្រទេស ព្រមទាំងមន្ត្រីតំណាងរដ្ឋាភិបាលកម្ពុជា។ ការចុះត្រួតពិនិត្យនៅតំបន់អានសេះ ក្នុងខេត្តព្រះវិហារដែលមានការសម្របសម្រួលដោយក្រសួងការពារជាតិ មានគោលបំណងវាយតម្លៃស្ថានភាពដោយផ្ទាល់ និងបញ្ជាក់ឡើងវិញនូវអធិបតេយ្យភាពរបស់កម្ពុជាបន្ទាប់ពីបទ

ឈប់បាញ់។ ក្នុងបេសកកម្មនេះ កងកម្លាំងប្រដាប់អាវុធកម្ពុជាបានបង្ហាញពីតម្លាភាពពេញលេញ និងបានបញ្ជាក់ជាថ្មីថា តំបន់អានសេះនៅតែស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជា។ មន្ត្រីមកពីប្រទេសដែលចូលរួម បានសម្តែងការគាំទ្រចំពោះដំណើរការសន្តិភាព និងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារបូរណភាពទឹកដីរបស់ខ្លួន។

នៅថ្ងៃទី០១ ខែសីហា វិទ្យាស្ថាន AVI បានចូលរួមក្នុងបទបង្ហាញបច្ចេកទេសដែលរៀបចំដោយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ដែលរៀបរាប់អំពីប្រភេទសំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) ដែលបានរកឃើញនៅក្នុងតំបន់រងផលប៉ះពាល់។ CMAC បានលើកឡើងពីហានិភ័យដែលគ្រាប់បែកទាំងនេះបង្កដល់ជនស៊ីវិល និងបង្ហាញពីយុទ្ធសាស្ត្របោសសម្អាតដែលកំពុងអនុវត្ត។ នៅថ្ងៃដដែល AVI បានចូលរួមជាមួយគណៈប្រតិភូការទូតក្នុងការធ្វើដំណើរទៅកាន់ស្រុកបន្ទាយអំពិល រួមទាំងតំបន់ជាំតែ ដែលមានការខូចខាតយ៉ាងធ្ងន់ធ្ងរពីការបាញ់ផ្លោងកាំភ្លើងធំ។ ទីតាំងវប្បធម៌ និងអរិយធម៌សំខាន់ៗត្រូវបានរកឃើញថាមានផលប៉ះពាល់យ៉ាងខ្លាំង រួមមានវត្តប្រាសាទតាមន្តសែនជ័យ សាលារៀនជុំវិញ រូបសំណាកព្រះពុទ្ធ តូបលក់វត្ថុអនុស្សាវរីយ៍ក្នុងស្រុក និងលំនៅដ្ឋានរបស់ប្រជាជន។

នៅថ្ងៃទី០២ ខែសីហា AVI ក៏បានធ្វើដំណើរទៅវត្តសូត្រនិគម ក្នុងខេត្តសៀមរាបជាកន្លែងដែលជនស៊ីវិលភៀសខ្លួនកំពុងស្នាក់នៅ។ ជម្រកបណ្តោះអាសន្ននេះ មានប្រជាពលរដ្ឋប្រមាណ ២០០,០០០ នាក់ ក្នុងនោះមានគ្រួសារមកពីខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តព្រះវិហារ ដែលបានឆ្លុះបញ្ចាំងពីទំហំនៃការផ្លាស់ទីលំនៅ និងចំនួនមនុស្សធម៌នៃជម្លោះនេះ។ នៅថ្ងៃដដែលនោះ AVI ក៏បានចូលរួមជាមួយ ឯកឧត្តម សួស យ៉ារ៉ា ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ដើម្បីពិនិត្យជម្រកជនភៀសសឹក នៅវត្តពុទ្ធសាសនាក្នុងស្រុកសូត្រនិគម ដែលបានអញ្ជើញចុះសួរសុខទុក្ខកុមាររាប់រយនាក់ ដែលត្រូវបានក្លាយជាជនភៀសសឹកដោយការឈ្លានពានរបស់ថៃតាមព្រំដែនកម្ពុជានាពេលថ្មីៗនេះ។

ការសង្កេតដែលទទួលបានពីដំណើរបេសកកម្មបានពង្រឹងការយល់ដឹងយ៉ាងស៊ីជម្រៅអំពីស្ថានភាពនៅលើមូលដ្ឋាន និងសារៈសំខាន់នៃការរក្សាបណ្តាញបើកចំហនៃការទំនាក់ទំនងរវាងតួអង្គរដ្ឋ និងមិនមែនរដ្ឋ ក៏ដូចជារវាងស្ថាប័នជាតិ និងដៃគូអន្តរជាតិ។ វាក៏បានសង្កត់ធ្ងន់ផងដែរអំពីតួនាទីសំខាន់របស់ស្ថាប័នស្រាវជ្រាវ ក្នុងការចងក្រងឯកសារផលប៉ះពាល់នៃវិបត្តិ ការកំណត់សេចក្តីត្រូវការជាក់ស្តែង និងការផ្តល់អនុសាសន៍គោលនយោបាយផ្អែកលើភស្តុតាងដែលសមស្របនឹងបរិបទកម្ពុជា។

វិទ្យាស្ថាន AVI សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ដែលបានជួយសម្រួលដល់បេសកកម្មដ៏សំខាន់នេះ។ យើងក៏សូមថ្លែងអំណរគុណចំពោះក្រសួងការពារជាតិ អភិបាលខេត្តឧត្តរមានជ័យ អគ្គនាយក CMAC អាជ្ញាធរមូលដ្ឋាន និងបណ្តាញសារ ព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ដែលបានចូលរួមសម្របសម្រួល ផ្តល់ព័ត៌មានសង្ខេបប្រកបដោយតម្លាភាព និងការចូលរួមចំណែកក្នុងការធានាឱ្យបាននូវការយល់ដឹងទូលំទូលាយអំពីស្ថានភាពនៅមូលដ្ឋាន។

ក្នុងនាមជាស្ថាប័នឈានមុខគេមួយរបស់កម្ពុជា AVI ឆ្លៀតយកឱកាសនេះដើម្បីស្វែងរកមធ្យោបាយសម្រាប់កិច្ចសន្ទនាគោលនយោបាយកាន់តែស៊ីជម្រៅ និងការសហការក្នុងតំបន់ក្នុងវិស័យនានាដូចជា ការឆ្លើយតបនឹងជម្លោះ សកម្មភាពមីន និងភាពធន់របស់សហគមន៍។ AVI នៅតែប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះអធិបតេយ្យភាពជាតិ ភាពសុខដុមរមនាក្នុងតំបន់ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងអស់។ បេសកកម្មនេះ បញ្ជាក់ឡើងវិញនូវការតាំងចិត្តរបស់យើងក្នុងការធានាថា បញ្ហារបស់សហគមន៍ដែលរងផលប៉ះពាល់ត្រូវបានទទួលការយកចិត្តទុកដាក់ និងមានដំណោះស្រាយឆ្លើយតបដោយសាមគ្គីភាព មេត្តាធម៌ និងកិច្ចសហប្រតិបត្តិការជាក់ស្តែង។

វិទ្យាស្ថាន AVI សូមអំពាវនាវឱ្យអាស៊ាន អង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិ និងស្ថាប័នមនុស្សធម៌ពាក់ព័ន្ធ បន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការដោះស្រាយតម្រូវការមនុស្សធម៌ជាបន្ទាន់របស់ជនស៊ីវិលដែលបានផ្លាស់ទីលំនៅ ពង្រឹងស្ថិរភាពព្រំដែន និងការលើកកម្ពស់សន្តិភាពក្នុងតំបន់។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥

AVI
ASIAN VISION INSTITUTE ORGANIZATION